Completing Absentee Notes and Notices

# ការបំពេញលិខិតសិស្សមិនបានមករៀន និងការផ្តល់ដំណឹងអំពីសិស្សមិនបានមករៀន

## ព័ត៌មានសំរាប់មាតាបិតា និងអ្នកមើលថែ

### នេះគឺជាការសំខាន់ដែលត្រូវប្រាប់សាលារៀន ប្រសិនបើកូនរបស់លោកអ្នកមិនបានមករៀន ហើយត្រូវផ្តល់នូវមូលហេតុនៃការមិនបានមករៀន។

នាយកសាលាត្រូវទទួលខុសត្រូវតាមច្បាប់ ក្នុងការរក្សាទុកនូវកំណត់ត្រានៃការទៅរៀនរបស់សិស្សឲ្យបានត្រឹមត្រូវ។

នាយកសាលាក៏ត្រូវទទួលខុសត្រូវផងដែរក្នុងការសំរេចពីមូលហេតុដែលបានផ្តល់ឲ្យអំពីការមិនបានមករៀនរបស់សិស្ស ថាតើសមហេតុផលឬទេ។

ពេលណាដែលអាចធ្វើទៅបាន មាតាបិតា និងអ្នកមើលថែត្រូវបានលើកទឹកចិត្តឲ្យផ្តល់នូវការពន្យល់អំពីការមិនបានមករៀន មុនការមិនបានមករៀនកើតឡើង។

នាយកសាលាមានសិទ្ធិសាកសួរមាតាបិតា ចំពោះការស្នើសុំមិនឲ្យកូនមករៀន។ នាយកសាលាក៏មានសិទ្ធិសាកសួរផងដែរ ចំពោះការពន្យល់ណាមួយដែលផ្តល់អំពីសិស្សមិនបានមករៀន។

ដើម្បីពន្យល់អំពីការមិនបានមករៀន មាតាបិតា និងអ្នកមើលថែអាចៈ

- ☐ ផ្ញើលិខិតខ្លី ទូរសារ ឬអ៊ីម៉េលមកសាលារៀន
- ☐ ទូរស័ព្ទមកសាលារៀន ឬ
- ☐ មកជួបសាលារៀន។

### លិខិតសិស្សមិនបានមករៀនជាពីរភាសា

មានលិខិតសិស្សមិនបានមករៀនជាពីរភាសាចំនួនបីច្បាប់ សំរាប់ជួយលោកអ្នកផ្តល់ព័ត៌មានទៅសាលារៀនអំពីការមិនបានមករៀនរបស់កូនលោកអ្នក។

Absentee note 1 (លិខិតសិស្សមិនបានមករៀនទី១) សំរាប់ប្រើពេលណាក្មេងមិនបានមករៀនមួយថ្ងៃពេញ។

Absentee note 2 (លិខិតសិស្សមិនបានមករៀនទី២) សំរាប់ប្រើពេលណាក្មេងមិនបានមករៀនលើសពីមួយថ្ងៃ។

Absentee note 3 លិខិតសិស្សមិនបានមករៀនទី៣) សំរាប់ប្រើពេលណាក្មេងមិនបានមករៀនផ្នែកនៃថ្ងៃ។

### ការផ្តល់ដំណឹងអំពីសិស្សមិនបានមករៀន

ប្រសិនបើសាលារៀនពុំបានទទួលការពន្យល់ប្រាប់អំពីការមិនបានមករៀនរបស់ក្មេងទេ គេអាចផ្ញើ Absentee Notice (ការផ្តល់ដំណឹងអំពីសិស្សមិនបានមករៀន) មួយច្បាប់ជូនលោកអ្នក ។

នាយកសាលាប្រើ Absentee Notice ដើម្បីទាក់ទងជាមួយមាតាបិតាក្នុងរយៈពេលពីរថ្ងៃនៃការមិនបានមករៀនដែលពុំមានការពន្យល់ប្រាប់។ ត្រូវបំពេញ Absentee Notice ជាភាសាអង់គ្លេស រួចផ្ញើមកសាលារៀនវិញក្នុងរយៈពេល៧ថ្ងៃ ដោយពន្យល់ប្រាប់អំពីមូលហេតុនៃការមិនបានមករៀន។

### ការបំពេញព័ត៌មានលំអិតនៃការមិនបានមករៀន

ផ្នែកនៃលិខិតសិស្សមិនបានមករៀន និងការផ្តល់ដំណឹងអំពីសិស្សមិនបានមករៀន ស្នើសុំលោកអ្នកឲ្យផ្តល់ព័ត៌មានលំអិតចំពោះការមិនបានមករៀន ឬការមិនបានមករៀនផ្នែកនៃថ្ងៃណាមួយរបស់កូនលោកអ្នក។

ដើម្បីឲ្យសាលារៀនអាចយល់អំពីមូលហេតុដែលផ្តល់ឲ្យ លោកអ្នកគួរបំពេញផ្នែកទាំងនេះជាភាសាអង់គ្លេស។ មូលហេតុទាំងឡាយដែលអាចកើតមានបានផ្តល់នៅលើសន្លឹកក្រដាសនេះ ហើយបានបកប្រែចេញជាភាសាអង់គ្លេស សំរាប់ឲ្យលោកអ្នកចម្លងដាក់ទៅក្នុងពាក្យបំពេញ ប្រសិនបើអាចធ្វើទៅបាន។

ប្រសិនបើលោកអ្នកមានការពិបាកយល់ពីលិខិតសិស្សមិនបានមករៀន ឬការផ្តល់ដំណឹងអំពីសិស្សមិនបានមករៀន ឬមានបញ្ហាក្នុងការបំពេញព័ត៌មានលំអិត លោកអ្នកអាចទូរស័ព្ទមកសាលារៀន ដើម្បីពន្យល់ប្រាប់អំពីមូលហេតុនៃការមិនបានមករៀនរបស់កូនលោកអ្នក។ ប្រសិនបើលោកអ្នកទូរស័ព្ទមកសាលារៀន លោកអ្នកពុំចាំបាច់បំពេញលិខិតជាលាយលក្ខណ៍អក្សរទេ។

### កិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយលោកអ្នកទាក់ទងជាមួយសាលារៀនរបស់កូនលោកអ្នក សូមទូរស័ព្ទទៅកិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទលេខ 131 450 រួចស្នើសុំអ្នកបកប្រែភាសារបស់លោកអ្នក។ អ្នកបកប្រែភាសានឹងទូរស័ព្ទទៅសាលារៀន ហើយនៅរង់ចាំតាមទូរស័ព្ទដើម្បីជួយលោកអ្នកនៅក្នុងការសន្ទនារបស់លោកអ្នក។ គេនឹងមិនគិតថ្លៃលោកអ្នកសំរាប់កិច្ចបំរើនេះទេ។

All content copyright
NSW Department of Education

## មូលហេតុទាំងឡាយដែលអាចកើតមានចំពោះការមិនបានមករៀន

### មូលហេតុផ្នែកពេទ្យ:

គ្រុនផ្ដាសាយ

ឈឺពោះ

ចុះរាក

ផ្ដាសាយ

ឈឺក្បាល / ឈឺមួយចំហៀងក្បាល (ប្រកាំង)

ចុកចាប់ខ្លាំង

គ្រុនក្ដៅ

បាក់ឆ្អឹង

ក្អួតចង្អោរ

ជម្ងឺឆ្លងរាលដាល រោគអុតស្វាយ

ឈាមច្រមុះ

រោគហឺត

រោលកន្ទួល

របួស

ការណាត់ជួបផ្នែកពេទ្យ

ការណាត់ជួបពិនិត្យមើលធ្មេញ

ការណាត់ជួបពិនិត្យមើលភ្នែក

ការណាត់ជួបព្យាបាលដោយធ្វើចលនា

ការណាត់ជួបគ្រូពេទ្យឯកទេស

ផ្សេងទៀត - ខ្ញុំនឹងទូរស័ព្ទមកសាលារៀនដើម្បីពន្យល់ប្រាប់

### មូលហេតុគ្រួសារ:

ពិធីបុណ្យសព

ការផ្លាស់ប្ដូរទីលំនៅ

ការមកដល់ ឬចេញដំណើរនៃបងប្អូនជិតស្និទ្ធមកពីបរទេស

ការទាក់ទិនដែលជៀសពុំរួចនៅក្នុងឧប្បត្តិហេតុធ្ងន់ធ្ងរក្នុងគ្រួសារ

ផ្សេងទៀត - ខ្ញុំនឹងទូរស័ព្ទមកសាលារៀនដើម្បីពន្យល់ប្រាប់

### មូលហេតុផ្សេងទៀត:

ព្រឹត្តិការណ៍អាក្រក់ ហើយពុំបានដឹងជាមុន ឧទាហរណ៍ ភ្លើងឆេះ ទឹកជំនន់។

ចូលរួមក្នុងព្រឹត្តិការណ៍ពិសេស ឧទាហរណ៍ ការចូលរួមនៅក្នុងពិធីបុណ្យសាសនា

ការសំរាកលំហែរបស់គ្រួសារ

មានបញ្ហាក្នុងការដឹកជញ្ជូន

ការយឺតយូរដែលមិនអាចជៀសរួច

ផ្សេងទៀត - ខ្ញុំនឹងទូរស័ព្ទមកសាលារៀនដើម្បីពន្យល់ប្រាប់

## Possible reasons for absence

### Medical reason:

Flu

Stomach-ache

Diarrhoea

Cold

Headache/Migraine

Strong pain

Fever

Broken bone

Vomiting

Infectious illness eg chicken pox

Nose bleed

Asthma

Rash

Injury

Medical appointment

Dental appointment

Optometry appointment

Physiotherapy appointment

Specialist appointment

Other - I will telephone the school to explain

### Family reason:

Funeral

Moving residence

Arrival or departure of an immediate relative from overseas

Unavoidable involvement in a serious family incident

Other - I will telephone the school to explain

### Other reason:

Misadventure and unforeseen events eg fire, flood

Participation in special event, eg attendance at a religious ceremony

Family holiday

Transport difficulty

Unavoidable delay

Other - I will telephone the school to explain